# កិច្ចព្រមព្រៀង

ថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០២០ នៅក្រុមហ៊ុន **នីចធី អឹភែរឹល (ខេមបូឌា) ខូអិលធីឌី** បានបើកកិច្ចប្រជុំមួយក្រោមអធិបតីភាពលោក Kim Pan Kon ជាតំណាងក្រុមហ៊ុន ស្ដីពីការព្យួរកិច្ចសន្យាការងារមួយរយៈដោយមូលហេតុដោយសារវត្ថុធាតុដើមដែលត្រូវផលិតត្រូវបានផ្អាកមិនអាចនាំចូលបាន និងផលិតផលដែលផលិតរួចហើយមិនអាចនាំចេញបាន ធ្វើឲ្យប៉ះពាល់ដល់សង្វាក់ផលិតកម្មមិនអាចដំណើរការបានពេញលេញក្នុងរយៈ ០២ ខែ។

សមាសភាពចូលរួម៖

1- ភាគីតំណាងរោងចក្រ

- លោក Kim Pan Kon តំណាងនាយករោងចក្រ
- លោក យី ស្រ៊ី ជាប្រធានរដ្ឋបាល និងជាអ្នកកត់ត្រា

2- ភាគីតំណាងកម្មករនិយោជិត

- លោកស្រី ឈន ស៊ីណាត
- លោក សុខ ប៊ុនធឿន
- លោក សយ ល័ក្ខ
- លោក ម៉ន ពិសិទ្ធ
- លោកស្រី ប៉ែន រតនា
- លោកស្រី ចាន់ ស្រស់
- លោក ជួន ចាន់ឆាយា
- លោក ឈិន សុខៃ
- លោក ស រក្សា

ក្រោយពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក ភាគីទាំងពីរបានឈានដល់កិច្ចព្រមព្រៀងដូចខាងក្រោម ៖

1- ក្រុមហ៊ុនសម្រេចព្យួរកិច្ចសន្យាការងារ កម្មករនិយោជិត ចំនួន ៨៧១ នាក់ ក្នុងចំណោមកម្មករសរុបចំនួន ៨៧១ នាក់ (ក្នុងនោះមានកម្មករនិយោជិតចំនួន ០៦ នាក់ មានពត៌មានមិនគ្រប់គ្រាន់) ក្នុងរយៈពេល ០២ ខែ ដោយគិតចាប់ពីថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០២០។

NEX-T APPAREL (CAMBODIA) Co., Ltd.

2- ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះខាងតំណាងកម្មករទាំងអស់បានឯកភាពគ្នាព្រមទទួលយកប្រាក់ឧបត្ថម្ភដែលក្រុមហ៊ុនផ្តល់ជូន៣០ដុល្លាអាមេរិកនិងប្រាក់ឧបត្ថម្ភដែលរដ្ឋាភិបាលផ្តល់ជូន ៤០ដុល្លាអាមេរិក ក្នុងមួយខែ ដោយយោងទៅតាមសេចក្តីណែនាំស្តីពីការព្យួរកិច្ចសន្យាការងារលេខៈ ០៤៥/២០ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២០ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

3- ក្រុមហ៊ុនបើកប្រាក់ឧបត្ថម្ភចំនួន ៣០ដុល្លាអាមេរិក មួយខែម្តង នៅរៀងរាល់ថ្ងៃទី ៣០ នៃខែឧសភា និងខែមិថុនា ឆ្នាំ២០២០។

4- ចប់ការព្យួរការងារកម្មករនិយោជិត ត្រូវមកចូលធ្វើការនៅកន្លែងដើមវិញ តាមតួនាទីភារកិច្ចរបស់ខ្លួន។

ការប្រជុំនេះចប់សព្វគ្រប់នៅវេលាម៉ោង១៥:៥០នាទី នាថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០២០ ដដែលក្រោមបរិយាកាសរីករាយ។

ថ្ងៃព្រហស្បតិ៍ ៣ កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០២០

បានឃើញនឹងឯកភាព

តំណាងនាយកក្រុមហ៊ុន

Kim Pan Kon

អ្នកកត់ត្រា

យី ស្រ៊ី

បានឃើញនឹងឯកភាព

តំណាងកម្មករ

ឈុន ស៊ីណាត
សុខ ប៊ុនធឿន
សយ លក្ខ

ម៉ន ពិសិទ្ធ
ប៉ែន រតនា
ចាន់ ស្រស់

ជួន ចាន់ឆាយ៉ា
ឈិន សុខៃ
ស រក្សា